ក្រសួងសាធារណការ និង ដឹកជញ្ជូន
MINISTRY OF PUBLIC WORKS AND TRANSPORT

# តាមដាន និងរាយការណ៍ ប្រចាំថ្ងៃដើម្បីទប់ស្កាត់ជម្ងឺ

## កូវីដ-១៩ (COVID-19)



វីដេអូណែនាំ

trace.covid19.mpwt.gov.kh/guideline




ស្កេនទីនេះ

trace.covid19.mpwt.gov.kh

សម្រាប់ការផ្តល់បច្ចេកទេសសូមទំនាក់ទំនង មណ្ឌលប្រឹក្សាយោបល់ លើសេវាសាធារណៈ:

**1275**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
លេខ:..០៥៤.......សជណ.សក.រប

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអនុវត្តវិធានការតាមដានស្ថានភាពសុខភាពផ្ទាល់ខ្លួនប្រចាំថ្ងៃ និងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩

ក្រសួងសាធារណការ និងដឹកជញ្ជូន សូមជម្រាបជូនដំណឹងដល់ **ឯកឧត្តម-លោកជំទាវ ជាថ្នាក់ដឹកនាំ លោក-លោកស្រីជាបុគ្គលិកមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាទាំងអស់ក្រោមឱវាទក្រសួង** មេត្តាជ្រាបថា៖ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលឡើងវិញនៃជំងឺកូវីដ-១៩ នាពេលថ្មីៗនេះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងស្នើសុំ **ឯកឧត្តម-លោកជំទាវ លោក-លោកស្រី**ទាំងអស់ បន្តធ្វើការបំពេញទម្រង់ឌីជីថលរាយការណ៍ពីស្ថានភាពសុខភាពផ្ទាល់ខ្លួនឱ្យបានទៀងទាត់ជារៀងរាល់ថ្ងៃ តាមរយៈប្រព័ន្ធគេហទំព័រដែលមានអាសយដ្ឋាន http://trace.covid19.mpwt.gov.kh ឬស្កេន QR Code ដូចបានជូនភ្ជាប់ខាងក្រោម។ ជាមួយគ្នានេះ ក្រសួងស្នើសុំ **ឯកឧត្តម-លោកជំទាវ លោក-លោកស្រី**ទាំងអស់ បន្តអនុវត្តនូវសេចក្តីណែនាំលេខ០១០ សក.រប ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ស្តីពីការអនុវត្តវិធានការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ ក្នុងក្រសួងសាធារណការ និងដឹកជញ្ជូន។

អាស្រ័យដូចបានគោរពនិងជម្រាបជូនខាងលើ សូម **ឯកឧត្តម-លោកជំទាវ ជាថ្នាក់ដឹកនាំ លោក-លោកស្រីជាបុគ្គលិកមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាទាំងអស់ក្រោមឱវាទក្រសួង** មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

ថ្ងៃអង្គារ ១០រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០

QR Code
តាមដានស្ថានភាពសុខភាព
របស់មន្ត្រីរាជការក្រសួងសាធារណការ និងដឹកជញ្ជូន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
លេខ: ០៧០ សក.រប

# សេចក្តីណែនាំ
# ស្តីពី
# ការអនុវត្តវិធានការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ ១៩ ក្នុងក្រសួងសាធារណការ និងដឹកជញ្ជូន

យោងតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ០១ សរណន ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០ និងសេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាលស្តីពីស្ថានភាពរីករាលដាលនៃជំងឺកូវីដ១៩ក្នុងប្រទេសកម្ពុជា និងក្នុងគោលបំណងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩នេះ ក្រសួងសាធារណការ និងដឹកជញ្ជូន សូមធ្វើការណែនាំដល់គ្រប់ថ្នាក់ដឹកនាំ ព្រមទាំងបុគ្គលិកមន្ត្រីរាជការទាំងអស់ក្រោមឱវាទក្រសួង មេត្តាចូលរួមសហការអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការមួយចំនួនដូចខាងក្រោម៖

១- បុគ្គលិកមន្ត្រីរាជការទាំងអស់ត្រូវបង្កើនការប្រុងប្រយ័ត្ន រក្សាអនាម័យ ដោយត្រូវលាងដៃនឹងសាប៊ូជាប្រចាំ ឬទឹកអាកុលសម្អាតសម្លាប់មេរោគឱ្យបានច្រើនដង និងត្រូវពាក់ម៉ាស់ឱ្យបានត្រឹមត្រូវ ក្នុងករណីចាំបាច់ ។

២- មន្ត្រីរដ្ឋបាលដែលធ្វើការដោយផ្ទាល់ទទួល-ប្រគល់ឯកសារ ឬមន្ត្រីចរាចរឯកសារដែលមានការទាក់ទងជាមួយអង្គភាពខាងក្រៅ ត្រូវពាក់ម៉ាស់ជាប្រចាំ និងប្រើប្រាស់ស្រោមដៃការពារ ហើយត្រូវលាងដៃដោយសាប៊ូ ឬទឹកអាកុលជាប្រចាំ មុន និងក្រោយពេលកាន់ឯកសារ ។

៣- រាល់ឯកសារចេញចូលទាំងឡាយ ត្រូវធ្វើការបាញ់ថ្នាំសម្លាប់មេរោគ ជាពិសេសឯកសារប្រគល់-ទទួល នៅច្រកចូល-ចេញនីមួយៗនៃការិយាល័យទទួលឯកសាររដ្ឋបាល ។

៤- រាល់ម៉ាស៊ីនឧបករណ៍ មធ្យោបាយបំរើការងារប្រចាំថ្ងៃ ដែលប្រើប្រាស់រួមគ្នាជាប្រចាំ កន្លែងសាធារណៈដែលមានការប៉ះពាល់ច្រើនដូចជា ជណ្តើរយន្ត បង្កាន់ដៃជណ្តើរ បន្ទប់ទឹក បន្ទប់ប្រជុំ បរិក្ខារប្រើប្រាស់ក្នុងការិយាល័យដូចជា តុ កៅអី ជាដើម ត្រូវមានវិធានការលាង ឬជូតសម្អាតដោយអាកុល ឬបាញ់ថ្នាំសម្លាប់មេរោគជាប្រចាំ ។

៥- ត្រូវប្តូរវិធីឥរិយាបថពីការចាប់ដៃ មកជាការសំពះគ្នាវិញ និងរក្សាគម្លាតសមរម្យមួយ (ក្នុងរង្វង់ពី ១,៥ ម៉ែត្រ ទៅ២ ម៉ែត្រ) ក្នុងកំឡុងពេលធ្វើការទំនាក់ទំនងការងារជាមួយបុគ្គលមកពីខាងក្រៅ និងសហការី ។

៦- ត្រូវកាត់បន្ថយការសមាជិកចូលរួមប្រជុំឲ្យបានជាអតិបរមា ដោយកិច្ចប្រជុំមួយអាចមានការចូលរួមពីបុគ្គលដែលពាក់ព័ន្ធចាំបាច់ប៉ុណ្ណោះ ហើយកន្លែងអង្គុយប្រជុំ ត្រូវរក្សាឱ្យមានគម្លាតពីគ្នា សម្រាប់មន្ត្រីនីមួយៗ ។

៧- ត្រូវជំរុញ និងលើកទឹកចិត្ត ដល់គ្រប់អង្គភាពក្រោមឱវាទក្រសួង ដោយប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងTelegram ក្នុងការបញ្ជូនប្រភេទឯកសារមួយចំនួន និងការឆ្លើយឆ្លងព័ត៌មានប្រចាំថ្ងៃ ដើម្បីបញ្ចៀសការជួបមុខគ្នាដោយផ្ទាល់ ។

៨- ភ្នាក់ងារសន្តិសុខត្រូវត្រួតពិនិត្យវាស់កំដៅខ្លួនឱ្យបានហ្មត់ចត់ (មិនលើសពី ៣៧,២ អង្សារ) ចំពោះមន្ត្រីដែលមកបំពេញការងារប្រចាំថ្ងៃ ឬភ្ញៀវដែលមានភារកិច្ចមកទំនាក់ទំនងការងារនៅតាមច្រកចេញចូល។ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងឡាយណាដែលវាស់កំដៅខ្លួនលើសពី ៣៧,២ អង្សារ ត្រូវបានអនុញ្ញាតឱ្យឈប់សម្រាកពីការងារ និងត្រូវទៅពិនិត្យសុខភាពដោយផ្ទាល់ខ្លួននៅមន្ទីរពេទ្យជាបន្ទាន់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ។

៩- សូមពិនិត្យមន្ត្រីដែលមកពីក្រៅប្រទេស ទាំងផ្លូវការ និងមិនផ្លូវការដោយប្រតិបត្តិតាមសារាចរណែនាំ របស់រាជរដ្ឋាភិបាល លេខ ០១ សរណនចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០ ស្តីពីវិធានការបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ ១៩ ។

ទទួលបានសេចក្តីណែនាំនេះ សូមថ្នាក់ដឹកនាំ គ្រប់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន អង្គភាព និងមន្ទីរក្រោមឱវាទក្រសួង ព្រមទាំងបុគ្គលិកមន្ត្រីរាជការទាំងអស់នៃក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវសហការអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មាតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ០៩រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២០

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

ស៊ុន_ចាន់ថុល

**កន្លែងទទួល៖**
- ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ
- ឯកឧត្តម លោកជំទាវ អនុរដ្ឋលេខាធិការ
- ឯកឧត្តមប្រតិភូ.ប្រធានអង្គភាពសហគ្រាសសាធារណៈ
- ឯកឧត្តមនាយកខុទ្ទកាល័យ
- គ្រប់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន
- គ្រប់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទក្រសួង
- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត
  *"ដើម្បីជ្រាប និងសហការអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ